**សេចក្តីជូនដំណឹងស្តីពីការប្រកាសជ្រើសរើស**

**អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC)**

**សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច**

| | |
|---|---|
| លេខគម្រោង | Project ID: |
| ឈ្មោះគម្រោង | សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា ( SRELFOOD Project 2 ) |
| មុខតំណែងជ្រើសរើស | អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ |
| រយៈពេលផ្តល់សេវា | *ចាប់ពី ៩-១២ ខែ (ផ្តល់សេវាបច្ចេកទេសរហូតចប់ការអនុវត្ត100%)* |

## ១. សាវតាគម្រោង

គម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា ( SRELFOOD Project 2 )" ដែលទទួលថវិកាគាំទ្រពីរាជរដ្ឋាភិបាលប្រទេសជប៉ុនតាមរយៈកម្មវិធីស្បៀងអាហារពិភពលោក (WFP) ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់នៃទឹកជំនន់ទៅលើសន្តិសុខស្បៀងរបស់គ្រួសារ និងសមហគមន៍រងផលប៉ះពាល់ដោយសារទឹកជំនន់ តាមរយៈផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលខេត្ត រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំគោលដៅអំពីការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ឬផែនការយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីបីឆ្នាំរំកិលរបស់ឃុំ ព្រមទាំងគាំទ្រដល់រដ្ឋបាលឃុំគោលដៅក្នុងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅឃុំគោលដៅចំនួន១៦ ស្រុកគោលដៅចំនួន០៨ នៃខេត្តគោលដៅចំនួន០៤ គឺខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ។

គម្រោងនឹងផ្តល់ថវិកាគាំទ្រគម្រោងមូលនិធិឃុំ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពជាអាទិភាពរបស់ឃុំដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ (CIP) និងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ថវិកាដែលគាំទ្រពីគម្រោងនឹងធ្វើការវិភាជប្រមាណ ៨៨% សម្រាប់ការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងចំនួនអតិបរិមា១២%នៃថវិកាត្រូវប្រើប្រាស់សម្រាប់ជួលអ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) ដើម្បីជួយក្រុមប្រឹក្សាឃុំក្នុងការសិក្សាបច្ចេកទេស ការរៀបចំគំនូសប្លង់ ការគណនាតម្លៃប៉ាន់ស្មាន ការរៀបចំគ្រោងការគម្រោងកិច្ចលទ្ធកម្ម ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំឆ្នាំ២០២២ ដែលបច្ចុប្បន្នសេវាបច្ចេកទេសត្រូវបានគាំទ្រដោយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីទទួលបច្ចេកទេសគាំទ្រឃុំ និងអនុវត្តតាមគោលការណ៍នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM) និងសៀវភៅបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ គ.ជ.អ.ប។

ក្នុងពេលបច្ចុប្បន្ននេះ តម្រូវការផ្តល់សេវាបច្ចេកទេសនេះ រួមទាំងការប្រមូលទិន្នន័យព័ត៌មាននៅមូលដ្ឋានការសិក្សាឋានលេខា និងលទ្ធភាពគម្រោង ការរៀបចំគ្រោងការគម្រោង ការប៉ាន់ស្មានតម្លៃគម្រោង ការរៀបចំព័ត៌មានគម្រោងពេញលេញ ការរៀបចំឯកសារដេញថ្លៃ ការគាំទ្រដំណើរការដេញថ្លៃ ការតាមដានត្រួតពិនិត្យ និងការអនុវត្តកិច្ចសន្យា។ល។ ការងារបច្ចេកទេសទាំងនេះ បានប្រតិបត្តិតាមគោលការណ៍នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM)។ ដើម្បីគាំទ្រកិច្ចការនេះ កម្មវិធីនឹងជ្រើសរើសអ្នកផ្តល់សេវាបច្ចេកទេសឯកជនមានគុណសម្បត្តិគ្រប់គ្រាន់ចំនួន០៦រូប សម្រាប់ជួយក្រុមប្រឹក្សាឃុំគោលដៅចំនួន១៦ ក្នុងខេត្តគោលដៅចំនួន៤ គឺខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ ជំនួសឱ្យសេវាគាំទ្របច្ចេកទេសលើការងារការសិក្សា គ្រោងការគម្រោងកិច្ចលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ ដែលផ្តល់ដោយមន្ត្រីគាំទ្របច្ចេកទេស

និងត្រូវសាងសង់ដោយអ្នកទទួលការ (អ្នកម៉ៅការ) និងចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ ដោយគាំទ្រហិរញ្ញវត្ថុដោយគម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD Project 2)"។

## ២. គោលបំណងនៃការផ្តល់សេវាបច្ចេកទេស

គោលបំណងនៃការផ្តល់សេវាបច្ចេកទេស[1] គឺជាការផ្តល់ឱ្យក្រុមប្រឹក្សាឃុំនូវសេវាបច្ចេកទេសប្រកបដោយគុណភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ តម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមមាន ការប្រមូលទិន្នន័យ ព័ត៌មាននៅមូលដ្ឋាន ការសិក្សាលទ្ធភាពគម្រោង ការរៀបចំគ្រោងការគម្រោង ការប៉ាន់ស្មានតម្លៃគម្រោង ការរៀបចំឯកសារព័ត៌មានគម្រោង ឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យាអនុវត្តគម្រោង ការគាំទ្រដំណើរការដេញថ្លៃ និងការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។ល។ គម្រោងនឹងត្រូវសាងសង់ដោយអ្នកទទួលការ (អ្នកម៉ៅការ) និងតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យាដោយគណៈកម្មការគ្រប់គ្រងគម្រោងឃុំ និងអ្នកផ្តល់សេវាបច្ចេកទេសឯកជន តាមរយៈការគាំទ្រហិរញ្ញវត្ថុដោយគម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD Project 2)" ដែលគាំទ្រថវិកាដោយកម្មវិធីស្បៀងអាហារពិភពលោក។

## ៣. ទីតាំង រយៈពេល និងពេលវេលានៃការផ្តល់សេវាបច្ចេកទេស

អ្នកផ្តល់សេវាបច្ចេកទេសឯកជន នឹងត្រូវជ្រើសរើសតាមរយៈកិច្ចសន្យាដាច់ពីគ្នា នៅតាមឃុំគោលដៅនីមួយៗ ដើម្បីផ្តល់សេវាបច្ចេកទេសចាប់ពីការសិក្សាគម្រោងរហូតបញ្ចប់ការអនុវត្តគម្រោង។ កិច្ចសន្យាផ្តល់សេវាបច្ចេកទេស និងបន្ទុកការងារមានសង្ខេបនៅក្នុងតារាងដូចខាងក្រោម៖

| ល.រ | ស្រុកគោលដៅ | ឃុំគោលដៅ | ឈ្មោះគម្រោង | ចំនួនគម្រោង | ចំនួន TSC |
|---|---|---|---|---|---|
| **១. ខេត្តកំពង់ឆ្នាំង** | | | | | |
| ១ | បរិបូរណ៍ | ខុនរ៉ង | 1. ជួសជុលផ្លូវក្រាលក្រួសក្រហម | ០២គម្រោង | ១នាក់ |
| ២ | ជលគិរី | ព្រៃគ្រី | 2. ជួសជុលផ្លូវថ្មភ្នំចំនួន២ខ្សែ | | |
| **២. ខេត្តពោធិ៍សាត់** | | | | | |
| ១ | បាកាន | អូរតាប៉ោង | 3. ស្តារប្រឡាយ | ០៥គម្រោង | ១នាក់ |
| | | | 4. ស្តារប្រឡាយ | | |
| | | បឹងបត់កណ្តាល | 5. ស្តារប្រឡាយ | | |
| | | | 6. ស្តារអាងស្តុកទឹក១កន្លែង | | |
| | | ស្នាមព្រះ | 7. ស្តារបឹងធម្មជាតិ១កន្លែង | | |
| ២ | កណ្តៀង | ស្រែស្តុក | 8. សាងសង់ផ្លូវក្រាលក្រួសក្រហម2ខ្សែ | ០៤គម្រោង | ១នាក់ |
| | | កញ្ចរ | 9. សាងសង់ផ្លូវក្រាលក្រួសក្រហម2 | | |
| | | អន្លង់វិល | 10. ស្តារប្រលាយ | | |
| | | | 11. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |
| **៣. ខេត្តបាត់ដំបង** | | | | | |

[1] ដូចបានពិពណ៌នាក្នុងសៀវភៅ ភីម ការផ្តល់សេវាទាំងនេះរួមបញ្ចូលទាំងការពិនិត្យមើលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ប៉ុន្តែការពិនិត្យមើលផ្នែកនេះមិនបានដាក់បញ្ចូលទៅក្នុងការងារផ្តល់សេវាបច្ចេកទេសឯកជននេះទេ។

| | | | | | |
|---|---|---|---|---|---|
| ១ | ស្រុកថ្មគោល | បឹងព្រីង | 12. ស្ពានប្រឡាយ | ០៥គម្រោង | ១នាក់ |
| | | តាម៉ឺន | 13. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |
| | | | 14. ស្ពានប្រឡាយ | | |
| | | អូរតាគី | 15. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |
| | | | 16. ស្ពានប្រឡាយ | | |
| ២ | ស្រុកមោងឫស្សី | កកោះ | 17. ស្ពានប្រឡាយប្រ | ០៦គម្រោង | ១នាក់ |
| | | | 18. ស្ពានប្រឡាយ | | |
| | | ជ្រៃ | 19. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |
| | | | 20. ស្ពានប្រឡាយ និងទ្វារទឹក | | |
| | | ឫស្សីក្រាំង | 21. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |
| | | | 22. ស្ពានប្រឡាយ | | |
| **៤. ខេត្តកំពង់ធំ** | | | | | |
| ១ | កំពង់ស្វាយ | កំពង់គោ | 23. ជួសជុលផ្លូវក្រាលក្រួសក្រហម | ០៣គម្រោង | ១នាក់ |
| ២ | ប្រាសាទសំបូរ | សំបូរណ៍ | 24. ជីកប្រឡាយ | | |
| | | | 25. ជួសជុលផ្លូវក្រាលក្រួសក្រហម | | |

## ៤. តម្រូវការលក្ខណៈសម្បត្តិ និងបទពិសោធន៍

ក្នុងពេលដំណើរការការងារ អ្នកផ្តល់សេវាបច្ចេកទេសឯកជនដែលមកពីផ្នែកឯកជន នឹងមិនរំពឹងថាទទួលបានការណែនាំច្រើនអំពីដំណើរការណែនាំពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM) និងសៀវភៅណែនាំបច្ចេកទេសរបស់ គ.ជ.អ.ប. ឡើយ។ ដូច្នេះ ក្នុងកំឡុងពេលចាប់ផ្តើមដំណាក់កាលនីមួយៗនៃការសិក្សាលទ្ធភាពគម្រោង រៀបចំគម្រោង រៀបចំលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់របស់អ្នកទទួលការ អ្នកផ្តល់សេវាបច្ចេកទេសឯកជននឹងទទួលបានការគាំទ្រ និងសម្របសម្រួលពីមន្ត្រីសម្របសម្រួលគម្រោង ទីចាត់ការផែនការ និងវិនិយោគនៅថ្នាក់ខេត្ត និងមន្ត្រីគម្រោង SRELFOOD Project 2 លើដំណើរការដែលត្រូវអនុវត្ត។ ដើម្បីមានលទ្ធភាពធ្វើការងារនេះឱ្យមានប្រសិទ្ធភាព បេក្ខជនត្រូវមានសមត្ថភាព និងបទពិសោធន៍ដូចខាងក្រោម៖

- ✓ យ៉ាងហោចណាស់មានកម្រិតជំនាញ ឬសញ្ញាបត្រវិស្វករជារាសាស្ត្រកសិកម្ម សំណង់ស៊ីវិល ឬជំនាញប្រហាក់ប្រហែល
- ✓ មានបទពិសោធន៍យ៉ាងតិច០៣ឆ្នាំក្នុងការសិក្សាវាស់ស្ទង់ គ្រោងប្លង់គម្រោង ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ (ជាពិសេសគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ឃុំ) ដូចជា ទំនប់ ប្រឡាយ សំណង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម ឬស្រះ។ល។
- ✓ មានចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា និងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
- ✓ ចេះប្រើកុំព្យូទ័រដូចជាកម្មវិធី Word, Excel, AutoCAD និងប្រព័ន្ធអ៊ិនធឺណេត អ៊ីម៉ែល
- ✓ ត្រូវតែស្ថិតនៅ ឬមានឆន្ទៈធ្វើការនៅក្នុងស្រុកគោលដៅ
- ✓ មានសម្ភារៈ ឧបករណ៍សិក្សាបច្ចេកទេស និងមធ្យោបាយធ្វើដំណើរបានញឹកញាប់ទៅតាមឃុំគោលដៅ។

- ☞ បុគ្គលដែលមានចំណាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV)។ មុនពេលដាក់ពាក្យសូមពិនិត្យមើលលក្ខខណ្ឌការងារសម្រាប់ផ្តល់សេវាបច្ចេកទេសឯកជន ដែលអាចទាញយកបានគេហទំព័រ គ.ជ.អ.ប. www.ncdd.gov.kh/jobs and procurement និងបណ្តាញសង្គមហ្វេសប៊ុករបស់លេខាធិកដារដ្ឋាន គ.ជ.អ.ប.។
- ☞ ដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV) ឯកសារពាក់ព័ន្ធនានា និងត្រូវបំពេញក្នុងលិខិតស្តីពីការសម្តែងចំណាប់អារម្មណ៍ (ឧបសម្ព័ន្ធ ក.១) ប្រកក្នុងស្រោមសំបុត្រដាក់ដាក់តាមអាសយដ្ឋាននៅមហាវិថីព្រះនរោត្តម អគារ T ជាន់ផ្ទាល់ដី ក្នុងបរិវេណក្រសួងមហាផ្ទៃ និងផ្ញើតាមអាស័យដ្ឋានអ៊ីម៉ែលខាងក្រោម។
- ☞ កាលបរិច្ឆេទឈប់ទទួលពាក្យនៅម៉ោង៥ **និង៣០នាទីល្ងាច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។**
- ☞ មានតែអ្នកដែលបានជាប់ក្នុងបញ្ជីសម្រាំងខ្លីនៃបេក្ខជនប៉ុណ្ណោះនឹងត្រូវជូនដំណឹងអំពីការសម្ភាស។

| | |
|---|---|
| សូមទំនាក់ទំនងព័ត៌មានបន្ថែម | ១. លោក **កែវ ប្រពៃ** ប្រធានការិយាល័យគ្រប់គ្រងគម្រោង (លេខាធិការដ្ឋាន គ.ជ.អ.ប.)<br>ទូរស័ព្ទលេខ: 099 787 007 អ៊ីមែល: prapey107@ncdd.gov.kh |
| | ២. លោកស្រី **វ៉ន សុគន្ធារី** មន្ត្រីគម្រោង (SRELFOOD 2-NCDDS)<br>ទូរស័ព្ទលេខ: 085 884 492 អ៊ីម៉ែល: sokuntheary.vorn@ncdd.gov.kh |

ថ្ងៃ...ចន្ទ ១១ កើត... ខែ...កត្តិក... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ភ្នំពេញ, ថ្ងៃទី...១៥... ខែវិច្ឆិកា ឆ្នាំ២០២១

**ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**

ឈុន ប៊ុនណារ៉